សេរីភាពមូលដ្ឋានអំឡុងពេលបោះឆ្នោតជាតិនៅកម្ពុជា ឆ្នាំ២០២៣

ក្រោយការបោះឆ្នោតឃុំ-សង្កាត់ដែលបានធ្វើឡើងកាលពីឆ្នាំមុន ការបោះឆ្នោតជាតិនៅកម្ពុជាក៏បានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០២៣។ សលាកប័ត្រនេះសង្ខេបលទ្ធផលទាក់ទងនឹងការឃ្លាំមើល និងការរំលោភបំពានសេរីភាពមូលដ្ឋានពលរដ្ឋ ក្នុងអំឡុងពេលពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ដែលគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានកត់ត្រាហេតុការណ៍ចំនួន ១៤៧ តាមរយៈការរាយការណ៍ពីហេតុការណ៍ និងការតាមដានប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងការបោះឆ្នោត។

ចំនួនហេតុការណ៍នៃការរឹតត្បិត ឬរំលោភបំពានទៅលើសេរីភាពមូលដ្ឋានទាក់ទងនឹងការបោះឆ្នោត

១០	១៣	៨	១៥	១៧	២៤	៣៩	១១	១០
មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា

រួមជាមួយសិទ្ធិផ្សេងទៀត សេរីភាពមូលដ្ឋានធានាដល់បុគ្គល និងសមាគមចូលរួមដោយសេរី ក្នុងសកម្មភាពពលរដ្ឋ និងនយោបាយ ដែលជាធាតុផ្សំដ៏សំខាន់មួយក្នុងការគាំទ្របរិយាកាសបោះឆ្នោតប្រកបដោយ សេរី និងយុត្តិធម៌ក្នុងប្រទេស។

ធាតុផ្សំសំខាន់ៗដែលគាំទ្រដល់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌រួមមាន៖

- សេរីភាពខាងការបញ្ចេញមតិ៖ អនុញ្ញាតឱ្យពលរដ្ឋ បេក្ខជនឈរឈ្មោះ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នក បោះឆ្នោតបញ្ចេញមតិដោយសេរី។
- សេរីភាពខាងសមាគម៖ អនុញ្ញាតបង្កើតគណបក្ស នយោបាយ និងចូលរួមយុទ្ធនាការនយោបាយ។
- សេរីភាពខាងការជួបប្រជុំ៖ ផ្តល់លំហដល់បុគ្គល និង អ្នកគាំទ្រនយោបាយ អាចជួបប្រជុំដោយសន្តិវិធី។

ហេតុការណ៍ដែលរឹតត្បិត ឬរំលោភបំពានសេរីភាពមូលដ្ឋាន



- ការរឹតត្បិត ១៦%
- ការរំលោភបំពាន ៨៤%

បុគ្គលចំនួន ៤២នាក់ ត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតជាតិនិងមិនឱ្យឈរឈ្មោះដាបេក្ខជនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រាជធានីភ្នំពេញ (គជ.ខប) ដែលចោទប្រកាន់ផ្អែកលើការអនុវត្តច្បាប់ថ្មីនេះ។

ក្របខណ្ឌច្បាប់៖ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ឃុំ-សង្កាត់ (មាត្រា ៣៥ ១៧១ ១៧២) និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (មាត្រា ២៣ ១៤២ ១៤៣)។

សេរីភាពខាងសង្គម

គម្រោងបានកត់ត្រា ១២៥ ហេតុការណ៍ទាក់ទងនឹងសេរីភាពខាងសមាគម។

ការរឹតត្បិត	ការរំលោភបំពាន
៣០	១០៦

៣ មន្ត្រីរាជការ ដែលជាសមាជិកគណបក្សភ្លើងទៀន ៣នាក់ ត្រូវបានដកចេញពីតំណែង

១០ ហេតុការណ៍ដែលសមាជិកគណបក្សជំទាស់ត្រូវបានវាយប្រហារលើរាងកាយ

៣២ ហេតុការណ៍ទាក់ទងនឹងការយោយឺតាមប្រព័ន្ធច្បាប់ រួមមានចំនួនមនុស្ស៖

សមាជិកគណបក្សបេះដូងជាតិចំនួន១៣នាក់ត្រូវបានកាត់ទោសពីបទក្លែងបន្លំ និងប្រើប្រាស់ឯកសារក្លែងបន្លំ ក្រោមច្បាប់ដែលតែងតែប្រើដើម្បីចោទប្រកាន់អ្នកនយោបាយជំទាស់។

គណបក្សភ្លើងទៀន និងគណបក្សមហាសាមគ្គីជាតិខ្មែរត្រូវបាន គ.ជ.ប ច្រានចោលចំពោះការចុះឈ្មោះ និងដកហូតសិទ្ធិ។

គណបក្សមហាសាមគ្គីជាតិខ្មែរ

គណបក្សភ្លើងទៀន

- នៅឆ្នាំ២០២២ គណបក្សភ្លើងទៀន បានឈ្នះសំឡេងឆ្នោត១៩% ដែលស្មើប្រមាណ ២,២០០ អាសនៈ។
- នៅខែឧសភា ឆ្នាំ២០២៣ គណបក្សភ្លើងទៀន ត្រូវបានបដិសេធពីការចុះបញ្ជីដោយសារតែមិនគ្រប់លក្ខខណ្ឌរបស់ គ.ជ.ប មុនពេលការបោះឆ្នោតជាតិ។

សេរីភាពខាងការបញ្ចេញមតិ

គម្រោងបានកត់ត្រា ៨២ ហេតុការណ៍ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ។

ការរឹតត្បិត	ការរំលោភបំពាន
៩	៧៣

ចំនួនហេតុការណ៍ដែលស្លាកគណបក្សនយោបាយត្រូវបានបំផ្លាញ ឬដកចេញដោយគ្មានការអនុញ្ញាត



- គណបក្សប្រជាជនកម្ពុជា ១
- គណបក្សខ្មែររួបរួមជាតិ ១
- គណបក្សភ្លើងទៀន ៤៣

ចាប់តាំងពីការបោះឆ្នោតជាតិ៖

- សមាជិកអតីតគណបក្សសង្គ្រោះជាតិចំនួន ៣៨រូប និងសមាជិកគណបក្សភ្លើងទៀន ៤ រូប ត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងពិន័យជាទឹកប្រាក់។

អ្នកគាំទ្រគណបក្សភ្លើងទៀន ម្នាក់ត្រូវបានគេគំរាមសម្លាប់ទាក់ទងនឹងការជំរុញស្លាកគណបក្ស។

សេរីភាពខាងការជួបប្រជុំ

ការរឹតត្បិត	ការរំលោភបំពាន
៣	១

ការអនុវត្តសេរីភាពខាងការជួបប្រជុំ ហាក់មានចំនួនតិចតួចក្នុងចំណោមសេរីភាពមូលដ្ឋានទាំងអស់ក្នុងអំឡុងពេលកត់ត្រានេះ ដោយមានតែ៤ហេតុការណ៍ប៉ុណ្ណោះដែលគម្រោងបានកត់ត្រា។

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ សកម្មជនប្រមាណជា ១០០ នាក់ មកពីគណបក្សជំទាស់ គឺគណបក្សភ្លើងទៀនបានប្រមូលផ្តុំគ្នាដោយសន្តិវិធីទាមទារឱ្យមានការដោះលែងសកម្មជនគណបក្សនេះដែលកំពុងជាប់ឃុំខ្លួនក្នុងពន្ធនាគារ។ អាជ្ញាធរខណ្ឌសែនសុខ បានរារាំងការប្រមូលផ្តុំដោយមូលហេតុបង្កឱ្យកកស្ទះចរាចរណ៍នៅមុខការិយាល័យគណបក្សភ្លើងទៀន។

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបន្តមើលឃើញនូវការយាយីផ្សេងៗចំពោះគណបក្សជំទាស់ ដែលរារាំងដល់ការចូលរួមក្នុងដំណើរការបោះឆ្នោតជាតិឆ្នាំ២០២៣ ដែលត្រូវបានអ្នកវិភាគនយោបាយជាច្រើនចាត់ទុកថាមិនសេរី និងយុត្តិធម៌។ ការព្យាយាមដកសិទ្ធិបេក្ខជនឬការយាយីសមាជិកគណបក្សជំទាស់ គឺធ្វើឱ្យប៉ះពាល់ដល់គោលការណ៍លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិរបស់ពលរដ្ឋ ក្នុងការជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី។

ការបោះឆ្នោតប្រកបដោយយុត្តិធម៌ និងបរិយាប័ន្ត មានសារៈសំខាន់សម្រាប់សង្គមប្រជាធិបតេយ្យ ដោយអនុញ្ញាតឱ្យមាននូវការបញ្ចេញមតិលើទិដ្ឋភាពនយោបាយចម្រុះ ដែលធានាបាននូវភាពស្របច្បាប់នៃរដ្ឋាភិបាលដែលជាប់ឆ្នោត។ តាមរយៈការជំរុញឱ្យមានបរិយាកាសដែលអនុញ្ញាតដល់ការចូលរួមយ៉ាងពេញលេញ និងប្រកបដោយខ្លឹមសារ ពីគ្រប់គណបក្សនយោបាយ កម្ពុជានឹងអាចពង្រឹងប្រជាធិបតេយ្យរបស់ខ្លួន និងធានាថាឆន្ទៈរបស់ពលរដ្ឋត្រូវបានគោរព និងឆ្លុះបញ្ចាំងនៅក្នុងលទ្ធផលបោះឆ្នោត។

ខែវិច្ឆិកា ឆ្នាំ២០២៣

CC BY NC SA